01072343

E343

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 03 / 2015
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** លោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ពេលវេលាដែលអង្គជំនុំជម្រះសាលាដំបូងមិនធ្វើសវនាការក្នុងឆ្នាំ ២០១៥

១. ដើម្បីជួយសម្រួលដល់ការរៀបចំផែនការការងារ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងទៅភាគីអំពីពេលវេលាដែលអង្គជំនុំជម្រះមិនធ្វើសវនាការក្នុងឆ្នាំ ២០១៥ ដែលមានដូចខាងក្រោមនេះ៖

ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១៥ (ពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ)

ថ្ងៃទី ១១ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៥ (ពិធីបុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ នរោត្តម សីហមុនី)

ថ្ងៃទី ២៩ ខែ មិថុនា ដល់ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ (ការឈប់សម្រាកពាក់កណ្តាលឆ្នាំ)

ថ្ងៃទី ១២ ដល់ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៥ (ពិធីបុណ្យភ្ជុំបិណ្ឌ)

ថ្ងៃទី ២៣ ដល់ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥ (ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង

01072344

E343

សំពះព្រះខែ អកអំបុក)

ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៥ ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ (បុណ្យណូអែល/បុណ្យចូលឆ្នាំសកល)

២. ពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ត្រូវបន្តរាប់នៅក្នុងអំឡុងពេលផ្អាកមិនធ្វើសវនាការ ដូចបានរៀបរាប់ខាងលើ។

៣. បើទោះបីជាថ្ងៃផ្អាកសវនាការខាងលើភាគច្រើនគឺជាថ្ងៃបុណ្យឈប់សម្រាកជាផ្លូវការរបស់ជាតិ និងអន្តរជាតិក្តី ក៏អង្គជំនុំជម្រះនឹងផ្អាកមិនធ្វើសវនាការនៅថ្ងៃឈប់សម្រាកជាសាធារណៈរយៈពេលខ្លីៗមួយថ្ងៃៗផ្សេងទៀត ដែលជាថ្ងៃបុណ្យឈប់សម្រាកផ្លូវការកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជាផងដែរ។ នាពេលកន្លងមក កាលបរិច្ឆេទនៃថ្ងៃឈប់សម្រាកជាសាធារណៈបន្ថែមទៀតរបស់ អ.វ.ត.ក នេះ ត្រូវបានការិយាល័យរដ្ឋបាលផ្ញើទៅភាគី នៅក្នុងសេចក្តីជូនដំណឹងរបស់ខ្លួនដែលមានចំណងជើងថា "ថ្ងៃបុណ្យឈប់សម្រាកជាផ្លូវការសម្រាប់ឆ្នាំ ២០១៥" ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដែលភ្ជាប់មកជាមួយឯកសារនេះ ជាឯកសារយោង។

៤. អង្គជំនុំជម្រះសូមបញ្ជាក់ថា ថ្ងៃផ្អាកមិនធ្វើសវនាការមិនមែនជាថ្ងៃឈប់សម្រាកឡើយ។ ថ្ងៃទាំងនោះ គ្រាន់តែជាថ្ងៃដែលអង្គជំនុំជម្រះសាលាដំបូងផ្អាកមិនធ្វើសវនាការក្នុងសំណុំរឿង ០០២/០២ តែប៉ុណ្ណោះ។ ក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះនឹងធ្វើការងារពាក់ព័ន្ធនឹងសេចក្តីសម្រេចនានា និងរៀបចំផែនការសម្រាប់ដំណាក់កាលសវនាការបន្តបន្ទាប់ទៀត។ រយៈពេលដែលអង្គជំនុំជម្រះផ្អាកមិនធ្វើសវនាការជាឱកាសសម្រាប់ភាគីនានាក្នុងការពិនិត្យមើលកំណត់ហេតុស្តាប់ចម្លើយពីសំណុំរឿងផ្សេងៗ ដែលត្រូវបានដាក់បង្ហាញជាបន្តបន្ទាប់។ រយៈពេលនេះក៏មានសារៈសំខាន់ជាចាំបាច់ផងដែរ សម្រាប់ការកោះប្រជុំគណៈកម្មាធិការរដ្ឋបាលតុលាការ និងកិច្ចប្រជុំពេញអង្គ ក្នុងករណីចាំបាច់។